**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១០ សរណន.

*រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៩*

# សារាចរណែនាំ

## ស្តីពី

## នីតិវិធី នៃការតែងតាំងមន្ត្រីរាជការស៊ីវិល

* * *

ទោះបីជាច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ អនុក្រឹត្យលេខ២០ អនក្រ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៧ ស្តីពី គោលការណ៍រួមនៃនីតិវិធីគ្រប់គ្រងមន្ត្រីរាជការស៊ីវិល សារាចរលេខ ០១ សរ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍ជ្រើសរើសអោយចូលក្នុងក្របខ័ណ្ឌរដ្ឋ និង គោលការណ៍ជ្រើសរើសបណ្តុះបណ្តាល វិជ្ជាជីវៈ នៃក្រសួងស្ថាប័ននានា សារាចរណែនាំលេខ ០២ សរណន ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការ ជ្រើសរើស និង តែងតាំងមន្ត្រីរាជការស៊ីវិល និង លិខិតបទដ្ឋានផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលបានដាក់ចេញ ជាបន្តបន្ទាប់ដើម្បីធ្វើអោយរដ្ឋបាលរបស់រដ្ឋមានលក្ខណៈ អព្យាក្រឹត្យ តម្លាភាព និង អភិបាលកិច្ចល្អ រាជរដ្ឋាភិបាល បានសង្កេតឃើញថា ការអនុវត្តន៍របស់ក្រសួងស្ថាប័ន និង ខេត្ត-ក្រុងមួយចំនួនក្នុងការជ្រើសរើសអោយចូល ក្នុងក្របខ័ណ្ឌរដ្ឋ និង ការតែងតាំងមន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌមុខងារសាធារណៈ នៅតែមានបាតុភាព មិនប្រក្រតីដែលផ្ទុយនឹងគោលការណ៍ និង នីតិវិធីដែលបានកំណត់ហើយមិនទាន់មានលក្ខណៈឯកភាពគ្នានៅ ឡើយ ។

ដើម្បីពង្រឹងការអនុវត្តន៍ច្បាប់ លិខិតបទដ្ឋាន និង លុបបំបាត់បាតុភាពមិនប្រក្រតីខាងលើ រាជរដ្ឋាភិបាលសូមធ្វើការណែនាំបន្ថែមដូចខាងក្រោម ៖

**១_ *ការតែងតាំងមន្ត្រីរាជការស៊ីវិលនៅក្រសួង_ស្ថាប័ន :***

-ត្រូវបន្តអនុវត្តអោយបានត្រឹមត្រូវតាមចំណុចទី២ ស្តីអំពីការតែងតាំងមុខតំណែងដែលកំណត់ ក្នុងសារាចរណែនាំលេខ ០២ សរណន ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩ ពោលគឺ :

ក_ការតែងតាំងអោយកាន់មុខតំណែងណាមួយ នៃមុខងារសាធារណៈ របស់ក្រសួងស្ថាប័ន ជា គោលការណ៍ត្រូវអនុវត្តចំពោះមន្ត្រីរាជការក្របខ័ណ្ឌ នៃក្រសួងស្ថាប័ននោះ ។

ខ_ការតែងតាំងត្រូវផ្អែកលើសំណូមពរ ភារកិច្ចជាក់ស្តែង សញ្ញាប័ត្រជំនាញ បទពិសោធន៍ការងារ របស់សាម៉ីជន អោយសមស្របទៅតាមតួនាទីភារកិច្ច និងរចនាសម្ព័ន្ធរបស់ក្រសួងនិមួយៗ ។

គ_ការតែងតាំងអោយកាន់មុខតំណែងណាមួយ ក្នុងមុខងារសាធារណៈ ត្រូវអនុវត្តអោយបានសម ស្រប ទៅតាមច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រីដែលមានចែងក្នុងមាត្រា ២៨ ជំពូកទី ៣ ស្តីពីសិទ្ធិក្នុងការតែងតាំង ។

-ត្រូវធ្វើការពិគ្រោះយោបល់អោយបានឯកភាពគ្នា ជៀសវាងដាច់ខាតមិនអោយមានបាតុភាពនៅក្នុងក្រសួងស្ថាប័នរបស់ខ្លួនមុននឹងលើកសំណើតែងតាំង ឬ ធ្វើសេចក្ដីសំរេចជាស្ថាពរ ។

-រាល់លិខិតបទដ្ឋានឯកត្តជនស្ដីពីការតែងតាំងមន្ត្រីរាជការស៊ីវិល ដូចជាព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាស ត្រូវដាក់ឆ្លងជាមុន ដើម្បីផ្ទៀងផ្ទាត់ផ្នែករដ្ឋបាលដោយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង ផ្នែកថវិកាដោយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដែលត្រូវចុះទិដ្ឋាការរៀង១ខ្លួន ។

-លិខិតបទដ្ឋានឯកត្តជនណាដែលគ្មានទិដ្ឋាការនោះ ត្រូវទុកជានិរាករណ៍ ។

## ២_ *ការតែងតាំងប្រធានមន្ទីរជំនាញខេត្ត_ក្រុង :*

-ការផ្ដួចផ្ដើមលិខិតតែងតាំងត្រូវធ្វើឡើងដោយក្រសួងស្ថាប័នជំនាញ ។

-ត្រូវធ្វើការពិគ្រោះយោបល់ អោយបានឯកភាពគ្នាក្នុងក្រសួងស្ថាប័ន ដើម្បីកំណត់យកបេក្ខជនដែលត្រូវតែងតាំង ។

-បន្ទាប់មកត្រូវពិគ្រោះយោបល់លើបេក្ខជនដែលត្រូវតែងតាំងនោះ ជាមួយអភិបាលខេត្ត_ក្រុងសាមុី ហើយអភិបាលខេត្ត_ក្រុងសាមុីនោះត្រូវធ្វើការពិគ្រោះយោបល់អោយមានការឯកភាពគ្នា ក្នុងជួរថ្នាក់ដឹកនាំខេត្ត_ក្រុង មុននឹងផ្ដល់យោបល់ឆ្លើយតប ។

-ក្នុងករណីមិនទាន់មានការឯកភាពរវាងក្រសួងស្ថាប័នសាមុី ជាមួយនឹងខេត្ត_ក្រុងនោះអភិបាលខេត្តក្រុងត្រូវលើកសំណើជូនក្រសួងមហាផ្ទៃ ដើម្បីជួយធ្វើការសំរបសំរួលជាមួយក្រសួងស្ថាប័នសាមុី ។

-ក្នុងករណីមិនអាចសំរបសំរួលបានក្រសួងមហាផ្ទៃ ឬ ក្រសួងស្ថាប័នសាមុីត្រូវលើកសំណើជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។

៣_ក្នុងករណីពិនិត្យឃើញថា លិខិតបទដ្ឋានឯកត្តជនស្ដីពីការតែងតាំងមន្ត្រីរាជការរបស់ក្រសួងស្ថាប័នធ្វើឡើងផ្ទុយនឹងច្បាប់ ឬ លិខិតបទដ្ឋានជាធរមាន ទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈត្រូវរាយការណ៍ជូនរាជរដ្ឋាភិបាល ដើម្បីសុំការអនុញ្ញាតិលុបចោលហើយត្រូវធ្វើការណែនាំក្រសួងស្ថាប័ននោះធ្វើអោយបានត្រឹមត្រូវឡើងវិញ ។

ទទួលបានសារាចរនេះ គ្រប់ក្រសួងស្ថាប័ន និង ខេត្ត_ក្រុងត្រូវខិតខំអនុវត្តតាមខ្លឹមសារខាងលើ ដោយស្មារតីទទួលខុសត្រូវ និង មានប្រសិទ្ធភាពខ្ពស់ ៕

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចម្លងជូន**

- *ខុទ្ទកាល័យព្រះមហាក្សត្រ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង_ស្ថាប័ន*
- *គ្រប់សាលាខេត្ត_ក្រុង*
- *ឯកសារ_កាលប្បវត្តិ*